ដើរជាមួយសហគមន៍
FH CAMBODIA

របាយការណ៍
ប្រចាំឆ្នាំ ២០២៥

ពង្រឹងប្រព័ន្ធមានភាពធន់
ដើម្បីសហគមន៍មានការរីកចម្រើន

តារាងមាតិកា

- ១. អំពីអង្គការ អេហ្វ អេក
- ២. សារពីនាយិកាប្រចាំប្រទេស
- ៣. សមិទ្ធផលសង្ខេប
- ៤. លទ្ធផលការងារប្រចាំប្រទេស
- ៥. ការអបអរសាទរសមិទ្ធផល និងបិទបញ្ចប់កម្មវិធីតំបន់ស្រុកស្វាយលើ១
- ៦. សមិទ្ធផលសំខាន់ៗ
- ៧. គម្រោងផ្តួចផ្តើមថ្មីៗ
- ៨. ការកសាងបណ្តាញការងារ និងភាពជាដៃគូ
- ៩. ទិដ្ឋភាពរួមផ្នែកហិរញ្ញវត្ថុ
- ១០. សេចក្តីថ្លែងអំណរគុណ

១. អំពីអង្គការ អេហ្វ អេភ

គុណតម្លៃរបស់យើង

- យើងដើរតាមព្រះយេស៊ូវគ្រីស្ទ
- ការងាររបស់យើង គឺជាការទំនាក់ទំនង
- យើងវិនិយោគដោយឈ្លាសវៃ និងផ្តោតលើលទ្ធផល
- យើងបម្រើដោយការបន្ទាបខ្លួន
- យើងចង់បន្តនូវភាពស្រស់បំព្រង ភាពល្អប្រសើរ និងសេចក្តីពិត

ចង្វាក់បេះដូងរបស់អង្គការ អេហ្វ អេភ

សេចក្តីថ្លែងរួមពីការងាររបស់យើង

យើងច្នៃបង្កើត អភិវឌ្ឍ និងផ្តល់នូវដំណោះស្រាយដោយការពន្លឿន ដែលបង្កើតនូវភាពធន់ ដើម្បីឱ្យកុមារ គ្រួសារ និងសហគមន៍ អាចរីកចម្រើន។

២. សារពីនាយិកាប្រចាំប្រទេស

ឆ្នាំសារពើពន្ធ ២០២៥ គឺជាដំណាក់កាលដ៏សំខាន់មួយនៃការផ្លាស់ប្តូរសម្រាប់អង្គការ អេហ្វ អេក កម្ពុជា ក្នុងការអនុវត្តគំរូកម្មវិធីថ្មីរបស់ខ្លួន ដែលមានឈ្មោះថា UNLOCK ។ គំរូកម្មវិធីនេះ ផ្តែកលើការអនុវត្តបែបប្រព័ន្ធ និងការផ្តោតលើសហគមន៍ជាចម្បង ដែលបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្តរបស់យើង ក្នុងការបម្រើសហគមន៍ តាមរយៈការពង្រឹងប្រព័ន្ធមូលដ្ឋាន និងការចាត់ទុកសហគមន៍ជាភ្នាក់ងារអភិវឌ្ឍន៍ ដែលមានសមត្ថភាព និងលទ្ធភាពក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍របស់ខ្លួន។

វឌ្ឍនភាពរបស់យើងនៅឆ្នាំនេះ អាចសម្រេចបានតាមរយៈការពង្រឹងភាពជាដៃគូដ៏រឹងមាំជាមួយរដ្ឋាភិបាល សង្គមស៊ីវិល ថ្នាក់ដឹកនាំមូលដ្ឋាន និងសហគមន៍ ដើម្បីដោះស្រាយបញ្ហា និងតម្រូវការឱ្យចំគោលដៅ។ កិច្ចសហប្រតិបត្តការទាំងនេះ ត្រូវបានអនុវត្តតាមរយៈកម្មវិធីមាគ៌ាឆ្ពោះទៅរកការរីកចម្រើនរួមមាន៖ សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត (កម្មវិធីសុខភាពអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ) លទ្ធផលសិក្សាល្អប្រសើរ និងការកសាងទ្រព្យសកម្ម (កម្មវិធីសន្តិសុខស្បៀង)។

ក្នុងការលើកកម្ពស់សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត កម្មវិធីត្រូវបានអនុវត្តផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវការទទួលបានអាហារូបត្ថម្ភដែលមានគុណភាព សេវាថែទាំសុខភាព និងការអនុវត្តទឹកស្អាត និងអនាម័យ សម្រាប់មាតា អ្នកថែទាំកុមារ និងមនុស្សចាស់។ តាមរយៈការសហការជាមួយមណ្ឌលសុខភាពចំនួន ១៨ អង្គការ អេហ្វ អេក កម្ពុជា បានពង្រឹងសមត្ថភាពក្រុមទ្រទ្រង់សុខភាពភូមិចំនួន ១៨៤នាក់ និងអ្នកស្ម័គ្រចិត្តនៃក្តីសង្ឃឹមចំនួន ៧៥០នាក់។ ក្រុមទ្រទ្រង់សុខភាពភូមិបានអនុវត្តសកម្មភាពយ៉ាងសកម្ម តាមរយៈការចុះសួរសុខទុក្ខតាមផ្ទះ និងការផ្សព្វផ្សាយចំណេះដឹង ដល់ម្តាយដែលមានកូនអាយុក្រោម ២ឆ្នាំ ចំនួន ២ ២៦០នាក់។ តាមរយៈការចុះសួរសុខទុក្ខតាមផ្ទះ និងបង្កើនចំណេះដឹងដល់ពួកគេ។ ជាមួយគ្នានេះ គំនិតផ្តួចផ្តើមបុរសជាគំរូ បានទទួលការចូលរួមពីបុរសចំនួន ៧១៧នាក់ដែលបានជួយជំរុញការផ្លាស់ប្តូរឥរិយាបថវិជ្ជមាន ក្នុងការចែករំលែកភារកិច្ច និងទំនួលខុសត្រូវចំពោះអាហារូបត្ថម្ភរបស់ម្តាយ និងកុមារ។

កម្មវិធីលទ្ធផលសិក្សាល្អប្រសើរ អង្គការ អេហ្វ អេក កម្ពុជា បានលើកកម្ពស់កន្លែងរៀនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការគាំទ្រ សម្រាប់កុមារដែលងាយរងគ្រោះ។ ដោយសហការជាមួយសាលាបឋមសិក្សាចំនួន ១២២ មត្តេយ្យរដ្ឋចំនួន ៧០ និងមត្តេយ្យសហគមន៍ចំនួន ៤០ យើងបានពង្រឹងសមត្ថភាពគ្រប់គ្រងសាលារៀន គុណភាពបង្រៀន និងការផ្តល់សម្ភារៈសិក្សា។ ការខិតខំទាំងនេះ បានផ្តល់អត្ថប្រយោជន៍ដល់កុមារចំនួន ២៦ ៧៩៨នាក់ ក្នុងនោះមានក្មេងស្រីចំនួន ១២ ៨៦៩នាក់ ហើយបានពង្រឹងតួនាទីរបស់អាណាព្យាបាល គ្រូបង្រៀន និងសហគមន៍ ក្នុងការគាំទ្រការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ។

កម្មវិធីកសាងទ្រព្យសកម្ម អង្គការ អេហ្វ អេក កម្ពុជា បានជួយពង្រឹងភាពធន់ និងស្ថិរភាពសេដ្ឋកិច្ចគ្រួសារ។ យើងបានគាំទ្រនូវការអនុវត្តកសិកម្មឱ្យប្រសើរ សម្រាប់កសិករ ៨៦៣នាក់ និងកសិករគំរូ ១៣០នាក់ ព្រមទាំងជំរុញក្រុមកសិករចំនួន ១១ក្រុម ដំណើរការប្រកបដោយប្រសិទ្ធភាព។ ការលើកកម្ពស់ការចូលរួមហិរញ្ញវត្ថុក្នុងសហគមន៍ ត្រូវបានអនុវត្តតាមរយៈក្រុមសន្សំ ១៦០ ក្រុម ដែលមានសមាជិកសរុប ៥ ៨៨៦នាក់ ក្នុងនោះមានស្ត្រី ៤ ២៥៤នាក់ ដែលជាកម្លាំងសំខាន់ក្នុងការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី និងលើកកម្ពស់សុខុមាលភាពគ្រួសារ។

ក្រៅពីកម្មវិធីអភិវឌ្ឍន៍ អង្គការ អេហ្វ អេក កម្ពុជា ក៏បានឆ្លើយតបទៅនឹងតម្រូវការជំនួយមនុស្សធម៌បន្ទាន់ បន្ទាប់ពីព្រឹត្តិការណ៍ជម្លោះព្រំដែន នៅខែកក្កដា។ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងមានការសម្របសម្រួលពីអង្គការមនុស្សធម៌ដៃគូ យើងបានផ្តល់ការគាំទ្រផ្នែកសុខភាព ទឹកស្អាត និងអនាម័យ ដល់ ៧ ២៩៩គ្រួសារ ដែលស្មើនឹងប្រជាពលរដ្ឋ ២៣ ៣៣៣នាក់។ ជំនួយស្បៀងអាហារបន្ទាន់ ត្រូវបានផ្តល់ដល់ ៨៩២ ខ្នងផ្ទះ ហើយគ្រួសារ ២១៥ ទៀត បានទទួលជំនួយតង់សម្រាប់ជម្រកបណ្តោះអាសន្ន។

អង្គការ អេហ្វ អេក កម្ពុជា នឹងបន្តអនុវត្តគំរូកម្មវិធី UNLOCK ទៅថ្ងៃខាងមុខ ដោយពង្រឹងភាពជាអ្នកដឹកនាំសហគមន៍ ពង្រីកកិច្ចសហការ និងលើកកម្ពស់សមត្ថភាពរបស់សហគមន៍ក្នុងការបញ្ចេញសំឡេង មានភាពម្ចាស់ការ និងទទួលបានសមត្ថភាព និងលទ្ធភាព។ គោលដៅអាទិភាពរបស់យើង នៅតែផ្តោតសំខាន់លើការកសាងប្រព័ន្ធសហគមន៍ឱ្យមានភាពអត់ធន់ ដើម្បីឱ្យគ្រួសារ និងប្រជាពលរដ្ឋកម្ពុជា មិនត្រឹមតែអាចឆ្លងកាត់បញ្ហាប្រឈមប៉ុណ្ណោះទេ ប៉ុន្តែអាចរីកចម្រើនបានយ៉ាងពេញលេញ។

លោកស្រី ពិន ទិត្យវាសនា / នាយកប្រចាំប្រទេស

៣. សមិទ្ធផលសង្ខេប

តើយើងជានរណា?

- អង្គការ អេហ្វ អេក ជាអង្គការគ្រីស្ទបរិស័ទដែលផ្តោតលើការងារអភិវឌ្ឍជាសាកល និងផ្តល់ជំនួយមនុស្សធម៌ តាមរយៈការរៀបចំ អភិវឌ្ឍ និងដោះស្រាយបញ្ហានានា អស់រយៈពេលជាង៥០ឆ្នាំមកហើយ ដើម្បីជួយឱ្យកុមារ គ្រួសារ និងសហគមន៍អាចរីកចម្រើន។ ចាប់តាំងពីឆ្នាំ ១៩៩០ មក អង្គការ អេហ្វ អេក បាននឹងកំពុងផ្តល់សិទ្ធិអំណាចដល់គ្រួសារ និងសហគមន៍ដែលងាយរងគ្រោះក្នុងប្រទេសកម្ពុជា។

វត្តមានអង្គការ អេហ្វ អេក នៅលើពិភពលោក

ទ្វីបអាស៊ី
- បង់ក្លាដេស
- កម្ពុជា
- ឥណ្ឌូណេស៊ី
- មជ្ឈិមបូព៌ា
- ហ្វីលីពីន
- វៀតណាម

ទ្វីបអាហ្វ្រិក
- ប៊ូរុនឌី
- សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ
- អេត្យូពី
- កេនយ៉ា
- ម៉ូសំប៊ិក
- រវ៉ាន់ដា
- អ៊ូហ្គង់ដា

ទ្វីបអាមេរិក និងតំបន់ការីប៊ីន
- បូលីវី
- សាធារណរដ្ឋដូមីនីក
- ក្វាតេម៉ាឡា
- ហៃទី
- នីហ្គារ៉ាហ្គា
- ប៉េរូ

១៩ ប្រទេស

ក្រុមគោលដៅរបស់យើង



- កម្មវិធីប្រចាំតំបន់ចំនួន ៩
- សហគមន៍ចំនួន ១៩៩
- ចំនួនគ្រួសារ ៥២ ៣៨៣
- អ្នកទទួលផលចំនួន ៩៨ ៩២៦
- បុរស ១៧ ១៨៥
- ស្ត្រី ២៩ ៨៥៦
- កុមារា ២៧ ១៩០
- កុមារី ២៤ ៦៩៥

គម្រោងផ្តួចផ្តើមថ្មីៗ

- គម្រោងទឹកដើម្បីសុខភាព
- គម្រោងកសាងសមត្ថភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈកម្មវិធីទឹកស្អាត និងអនាម័យ និងកម្មវិធីមុខរបរចិញ្ចឹមជីវិតប្រកបដោយចីរភាព
- គម្រោងលើកកម្ពស់ការសិក្សា តាមរយៈបច្ចេកវិទ្យា
- គម្រោងកៀរគរពួកជំនុំសម្រាប់ការបំផ្លាស់ប្តូរសហគមន៍

ភាពជាដៃគូ

ម្ចាស់ជំនួយជាសាខារបស់អង្គការអេហ្វ អេក	FHUS (Food for the Hungry), FH Canada (Food for the Hungry Canada), JIFH (Japan International Food for the Hungry)
ម្ចាស់ជំនួយ Grant	TAI (Transform Aid International), GPCCC (Greater Phoenix Chinese Christian Church), Rotary Club of Los Gatos and Magnuson Trust

៤.លទ្ធផលការងារប្រចាំប្រទេស

ការកសាងទ្រព្យសកម្ម (សន្តិសុខស្បៀង និងមុខរបរចិញ្ចឹមជីវិត)

៥៦.៦០%	គ្រួសារទទួលទានអាហារចម្រុះ ៦ក្រុម ឬច្រើនជាងនេះ ក្នុងរយៈពេល២៤ម៉ោងចុងក្រោយ
១១.៨ ខែ	ចំនួនខែជាមធ្យមនៃគ្រួសារដែលមានអាហារហូបគ្រប់គ្រាន់
៣.៤%	គ្រួសារមានបទពិសោធជួបប្រទះភាពស្រេកឃ្លានកម្រិតមធ្យម ឬធ្ងន់ធ្ងរ

លទ្ធផលសិក្សាល្អប្រសើរ (ការអប់រំ)

៤៦.៨% អ្នកថែទាំកុមារអាយុ 0-៦ឆ្នាំ ដែលបានចូលរួមក្នុងសកម្មភាពចំនួន ៤ ឬច្រើនជាងនេះ ដើម្បីលើកកម្ពស់ការរៀនសូត្រក្នុងរយៈពេល ៣ថ្ងៃចុងក្រោយ

៣១.២% អ្នកថែទាំកុមារអាយុ 0-១៥ ឆ្នាំ ដែលបានចូលរួមរៀនបានចំនួន៥មេរៀន ឬច្រើនជាងនេះ ដែលផ្តល់ ជំនាញនៃការជំរុញទឹកចិត្តកុមារ និងការត្រៀមខ្លួនរួចរាល់សម្រាប់ការចូលរៀនថ្នាក់ដំបូងសម្រាប់កុមារអាយុ 0-៦ ឆ្នាំ

៣៨.១% អ្នកថែទាំកុមារអាយុ 0-១៥ ឆ្នាំ ដែលបានចូលរួមរៀនបានចំនួន ៤ ឬច្រើនជាងនេះ នូវជំនាញ និងការអនុវត្តដើម្បីគាំទ្រភាពជោគជ័យកុមារនៅកម្រិតថ្នាក់ដំបូង

៣៤% អ្នកថែទាំកុមារ (រៀនថ្នាក់ទី១-ទី៣) ដែលអាចប្រាប់អំពីសមត្ថភាពចំនួនបីដែលកុមារត្រូវចេះនៅចុងឆ្នាំសិក្សា ដើម្បីធានាថាពួកគេបញ្ចប់ថ្នាក់នីមួយៗប្រកបដោយជោគជ័យ

សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត (សុខភាព អាហារូបត្ថម្ភ និងទឹកស្អាត និងអនាម័យ)

៧១.៩%	កុមារអាយុ ០-៥ ខែ ដែលបានបំបៅដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងរយៈពេល៦ខែ
៤៧.២%	កុមារអាយុ ៦-២៣ ខែទទួលបានរបបអាហារចម្រុះមុខ
៨៤.១%	ស្ត្រីដែលមានកូនអាយុក្រោម២ឆ្នាំបានបរិភោគរបបអាហារចម្រុះមុខក្នុងរយៈពេល ២៤ ម៉ោងចុងក្រោយ
៩១.៧%	ស្ត្រីដែលមានកូនអាយុ ០-២៣ ខែបានពិនិត្យផ្ទៃពោះមុនសម្រាល ៤ដង ឬច្រើនជាងនេះអំឡុងពេលមានផ្ទៃពោះ
៨៦.៨%	% កុមារអាយុ ១២-២៤ ខែ បានចាក់វ៉ាក់សាំងការពារជំងឺគ្រប់ចំនួន

សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត

៩២%	ខ្ទង់ផ្ទះដែលមានកន្លែងលាងដៃដែលមានសាប៊ូ និងទឹក
៧៩.៥%	គ្រួសារដែលមានបង្គន់ប្រើជាមូលដ្ឋាន ហើយមិនចែករំលែកជាមួយគ្រួសារផ្សេងទៀត
៨៥.៥%	ស្ត្រីដែលមានកូនអាយុ ០-២៣ ទទួលបានការគ្រប់គ្រង និងព្យាបាលជំងឺរាកបានត្រឹមត្រូវ នៅពេលដែលពួកគាត់មានជំងឺរាក
៧៥%	មណ្ឌលសុខភាពក្នុងតំបន់គោលដៅមានទឹកស្អាតប្រើប្រាស់ជាមូលដ្ឋាន
១០០%	មណ្ឌលសុខភាពក្នុងតំបន់គោលដៅមានបង្គន់កែលម្អជាមូលដ្ឋានប្រើប្រាស់

គម្រោងអភិវឌ្ឍន៍ទំនាក់ទំនងសហគមន៍

៥៣.0%	អ្នកថែទាំកុមារដែលវាយតម្លៃប្រសិទ្ធភាពនៃអ្នកដឹកនាំសហគមន៍របស់ពួកគេថា "ខ្ពស់" ឬ "ខ្ពស់ណាស់"
៧៧.៥%	អ្នកថែទាំកុមារ ដែលបានលើកឡើងថាសហគមន៍របស់ពួកគេមានសុវត្ថិភាព និងត្រូវបានការពារចំពោះកុមារ
៨៧.៣%	អ្នកថែទាំកុមារ ដែលមានកូនជាកុមារដៃគូ(RC)ពេញចិត្តនឹងកម្មវិធីអភិវឌ្ឍន៍របស់អង្គការ អេហ្វ អេក ។

៥. ការអបអរសាទរសមិទ្ធផល និងបិទបញ្ចប់ កម្មវិធីតំបន់ស្រុកស្វាយលើ១

ការបិទបញ្ចប់ កម្មវិធីតំបន់ស្រុកស្វាយលើ១

សហគមន៍ (ភូមិ) ចំនួន១២ បានបង្កើតសមិទ្ធផល និងបិទបញ្ចប់។

លទ្ធផលសិក្សាល្អប្រសើរ

សូចនាករ	ទិន្នន័យដើមគ្រា (២០១៥)	លទ្ធផលចុងគ្រា (២០២៥)
ភាគរយនៃអ្នកថែទាំកុមារអាយុ ០-៦ ឆ្នាំ ដែលបានអនុវត្តនូវយុទ្ធសាស្ត្រការពារកូនៗរបស់ពួកគេពីភាពតានតឹង(ស្ត្រេស) បានលើសពី១យុទ្ធសាស្ត្រ។	**១៥.៦%**	**៩០.២%**
ភាគរយនៃអ្នកថែទាំកុមារដែលមានអាយុ ៧-១៥ឆ្នាំ ដែលបានរៀបចំកន្លែងនៅក្នុងផ្ទះ(ឬក្បែរផ្ទះ)សម្រាប់កូនរៀន។	**២៦.៣%**	**៩៧.១%**
ភាគរយនៃអ្នកថែទាំកុមារដែលមានអាយុ ៧-១៥ឆ្នាំ ដែលបានពិនិត្យកិច្ចការផ្ទះរបស់កូនយ៉ាងហោចណាស់ពីរដងក្នុងរយៈពេល៧ថ្ងៃចុងក្រោយ។	**៣៨.៦%**	**៨៩.២%**
ភាគរយនៃកុមារអាយុ ៧-១៥ឆ្នាំ បានអានសៀវភៅ ឬអានសៀវភៅឱ្យកុមារផ្សេងទៀតនៅក្នុងផ្ទះស្តាប់ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ។	**៣៣%**	**៨៩%**

ការកសាងទ្រព្យសកម្ម

សូចនាករ	ទិន្នន័យដើមគ្រា (២០១៥)	លទ្ធផលចុងគ្រា (២០២៥)
គ្រួសារទទួលទានអាហារចម្រុះ ៦ក្រុម ឬច្រើនជាងនេះ	**៦.៣**	**៩.១**
ចំនួនខែជាមធ្យមនៃការមានអាហារហូបគ្រប់គ្រាន់ក្នុងគ្រួសារ	**១០.៦**	**១២**
ភាគរយកសិករដែល បានពង្រឹងការអនុវត្តបច្ចេកទេសជាំដុះ (បច្ចេកវិទ្យាកសិកម្ម) ក្នុងរយៈពេល១២ខែចុងក្រោយ តាមការផ្សព្វផ្សាយបច្ចេកទេស	**៩២%**	**៩៨%**

សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត និងទឹកស្អាត និងអនាម័យ

សូចនាករ	ទិន្នន័យដើមគ្រា (២០១៥)	លទ្ធផលចុងគ្រា (២០២៥)
ភាគរយនៃស្ត្រីដែលមានកូនអាយុក្រោម២ឆ្នាំបាន បរិភោគរបបអាហារចម្រុះមុខ ចាប់ពី៤មុខឡើងទៅ	៦០%	៨៤.៩%
ភាគរយនៃខ្នងផ្ទះដែលប្រើពិធីបន្សុទ្ធទឹកមុនពេលផឹក ក្នុងរយៈពេល២៤ម៉ោងមុន	១៧.៣%	៩២.៣%
ភាគរយនៃខ្នងផ្ទះដែលមានកន្លែងលាងដៃដែលមាន សាប៊ូនិងទឹក	៧.៣%	១០០%
ភាគរយនៃខ្នងផ្ទះមានបង្គន់អនាម័យដែលមានការ កែលម្អប្រើប្រាស់ប្រចាំគ្រួសារដោយមិនចែករំលែក ជាមួយផ្ទះអ្នកជិតខាង	៨២%	៩៧.២%
ភាគរយនៃខ្នងផ្ទះមានប្រភពទឹកកែលម្អសម្រាប់ផឹក ប្រចាំថ្ងៃ	៣.៨%	៧២%

៦. សមិទ្ធផលសំខាន់ៗ

៦.១ ការកសាងទ្រព្យសកម្ម

គោលដៅ៖ ការបង្កើតទ្រព្យសកម្ម (សន្តិសុខស្បៀង និងមុខរបរចិញ្ចឹមជីវិត) បង្កើតមូលដ្ឋានគ្រឹះសេដ្ឋកិច្ចដែលមានស្ថេរភាព និងធន់សម្រាប់គ្រួសារ និងសហគមន៍។ តាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ និងមិនមែន ហិរញ្ញវត្ថុ ជំរុញភាពជាសហគ្រិន និងការរួមបញ្ចូលបុគ្គលទៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម វាផ្តល់អំណាចដល់កសិករឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

លទ្ធផលរំពឹងទុកទី១៖

បង្កើនលទ្ធភាពទទួលបាន និងលទ្ធភាពរកបានអាហារពេញមួយឆ្នាំអោយបានគ្រប់គ្រាន់ មានភាពចម្រុះ និងសំបូរអាហារូបត្ថម្ភ ដោយគ្រួសារទាំងអស់នៅក្នុងសហគមន៍គោលដៅ និងបង្កើនសុវត្ថិភាពប្រាក់ចំណូល និងចម្រុះសម្រាប់គ្រួសារងាយរងគ្រោះនៅក្នុងសហគមន៍គោលដៅ

លទ្ធផលរំពឹងទុកទី២៖

បង្កើនសុវត្ថិភាពប្រាក់ចំណូល និងចម្រុះភាពសម្រាប់គ្រួសារងាយរងគ្រោះនៅក្នុងសហគមន៍គោលដៅ

លទ្ធផលរំពឹងទុកទី៣៖

លើកកម្ពស់ស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ និងតម្លៃទីផ្សារផលិតផលកសិកម្មនៅក្នុងសហគមន៍គោលដៅ

ក្រុមគោលដៅដែលយើងធ្វើការជាមួយ៖

- ១៣០ កសិករគំរូចំនួន
- ៧ សហគមន៍កសិកម្ម
- ១១ បណ្តុំកសិករ
- ១៦៩ ក្រុមសន្សំប្រាក់
- ៨៦៣ អ្នកស្ម័គ្រចិត្តកសិកម្ម
- ៤៩ សាលាបឋមសិក្សាថ្នាក់ទី ៤-៦
- ៣ សាលាអនុវិទ្យាល័យ

ការកសាងទ្រព្យសកម្ម

- ៣.៤% គ្រួសារមានបទពិសោធភាពស្រេកឃ្លានកម្រិតមធ្យមនៅក្នុងតំបន់គោលដៅនៅឆ្នាំសារពើពន្ធ ២០២៥
- ១១.៨ខែ ចំនួនខែជាមធ្យមនៃគ្រួសារដែលមានអាហារហូបគ្រប់គ្រាន់
- ៥៦.៦% គ្រួសារទទួលទានអាហារចម្រុះ ៦ក្រុម ឬច្រើនជាងនេះ
- ៥ ៨៨៦ (ស្រី ៤ ២៥៤នាក់) ប្រជាជនក្នុងសហគមន៍ ចូលរួមយ៉ាងសកម្មក្នុងក្រុមសន្សំប្រាក់ចំនួន ១៦៩ ដើម្បីសន្សំប្រាក់ និងការរៀនសូត្រ
- ១ ២១៤ (ស្រី៩៥៩នាក់) សមាជិកក្រុមសន្សំ និងជាបណ្តុំកសិករត្រូវបានបណ្តុះបណ្តាលអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុគ្រួសារ និងការធ្វើផែនការ និងការអភិវឌ្ឍន៍អាជីវកម្ម
- ១ ៩៨៧ (អ្នកដឹកនាំស្ត្រីចំនួន ១ ៥៤០នាក់) សមាជិកសហគមន៍នៃក្រុមសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ គោលការណ៍នៃការគ្រប់គ្រងក្រុម តួនាទី និងការទទួលខុសត្រូវ និងការកត់ត្រា
- ១៤ ក្រុមសន្សំប្រាក់ ត្រូវបានទទួលស្គាល់ជាផ្លូវការជាក្រុមសន្សំប្រាក់ សហគមន៍ដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដើម្បីជួយសម្រួលដល់ការសន្សំ និងកម្ចីនៅក្នុងសហគមន៍របស់ពួកគេ
- ៤៦៨ (ស្រី ៣៧៤នាក់) កសិករគំរូ ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ អ្នកស្ម័គ្រចិត្តសហគមន៍បានទទួលវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មឆ្លាតវៃ (សួនបន្លែ បច្ចេកទេសចិញ្ចឹមមាន់ ត្រី កង្កែប) ដើម្បីផ្សព្វផ្សាយចំណេះដឹងបន្តដល់សមាជិកសហគមន៍
- ១០០ (ស្រី៤០នាក់) កសិករគំរូ ត្រូវបាន បណ្តុះបណ្តាលអំពីបច្ចេកទេសប្រព័ន្ធកសិកម្មចម្រុះ
- ៨២៩ (ស្រី ៥៤៤នាក់) កសិករក្រីក្របាន បណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្មឆ្លាតវៃ (សួនបន្លែ សួនរង្វង់ សួនប្រើប្រាស់ប្រព័ន្ធដំណក់ទឹក ការចិញ្ចឹមមាន់ ទា ការចិញ្ចឹមត្រី និងការចិញ្ចឹមកង្កែប ដែលសម្របទៅនឹងការប្រែប្រួលអាកាសធាតុ)
- ១ ០៨០ (ស្រី ៦៥៤នាក់) កសិករដែលងាយរងគ្រោះទទួលបានកញ្ចប់គាំទ្រធាតុចូលកសិកម្មដូចជាគ្រាប់ពូជដំណាំ ពូជមាន់ និងពូជទា ពូជត្រី និងកង្កែប សម្ភារៈសិកម្ម និងចំណីសត្វ ដើម្បីចាប់ផ្តើមផលិតកម្មកសិកម្មរបស់ពួកគេ
- ១៦ (ស្រី៧នាក់) សមាជិកគណៈកម្មាធិការសហគមន៍កសិកម្ម បានទទួលការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ ការគ្រប់គ្រងអាជីវកម្ម និងការកត់ត្រា
- ៨៨៧ (ស្រី ៤៧០នាក់) សិស្សមកពីសាលារៀន ចំនួន ១១ ត្រូវបានបណ្តុះបណ្តាលអំពីកសិកម្មវៃឆ្លាតលើការដាំដុះបន្លែ ការចិញ្ចឹមកង្កែប និងការចិញ្ចឹមត្រី
- ៧៤ សាលារៀន បានទទួលការគាំទ្រនូវធាតុចូលបង្កើតសួនមេត្រីបរិស្ថានដូចជា គ្រាប់ពូជ សម្ភារៈថៃសួនសម្ភារៈកសិកម្មសម្រាប់ការចាប់ផ្តើមអនុវត្តសួនច្បារ កូនត្រីអណ្តែង ចំណី និងសម្ភារៈចិញ្ចឹម។

ផ្លូវទៅកាន់ការចាប់ផ្តើមថ្មី៖ យើងរួមគ្នាដាំគ្រាប់ពូជនៃភាពធន់ និងប្រមូលផលក្តីសង្ឃឹម!

លោក ផ្លយ ចាន់រស្មី អាយុ ៣៦ឆ្នាំ ជាគ្រូបង្រៀន និងជាកសិករគំរូនៅភូមិទន្លេស បានក្លាយជាធនធាននៃការបំផុសគំនិតក្នុងសហគមន៍របស់គាត់។ ជីវិតពួកគាត់ធ្លាប់លំបាកខ្លាំងណាស់ នៅក្នុងគ្រួសារមានគ្នាប្រាំនាក់។ ប្រាក់បៀវត្សរ៍បង្រៀនរបស់គាត់មិនអាចផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃបានទេ ហើយការព្យាយាមធ្វើស្រែចម្ការ និងចិញ្ចឹមសត្វជារឿយៗបរាជ័យ។ លោកបានរំឭកថា៖ «ទោះបីជាខ្ញុំជាគ្រូបង្រៀន ប៉ុន្តែយើងខ្វះចំណេះដឹងផ្នែកកសិកម្ម ខ្ញុំមានអារម្មណ៍តានតឹង និងព្រួយបារម្ភអំពីវិធីផ្តល់អនាគតឱ្យកូនខ្ញុំបានល្អ»។

នៅឆ្នាំ ២០២២ អ្វីៗបានចាប់ផ្តើមផ្លាស់ប្តូរនៅពេលដែលលោក ចាន់ រស្មី បានចូលរួមក្នុងគម្រោងសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់អង្គការ អេហ្វ អេក កម្ពុជា ។ ទោះបីជាមានការតស៊ូផ្នែកហិរញ្ញវត្ថុ និងបញ្ហាប្រឈមនៃជម្លោះព្រំដែនក៏ដោយ គាត់បានទទួលយកការបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មវៃឆ្លាត និងខ្សែច្រវាក់តម្លៃទីផ្សារ។ គាត់បានរៀនពីរបៀបចិញ្ចឹមមាន់ និងដាំបន្លែនៅក្នុងទីធ្លាខាងក្រោយ និងស្រះសហគមន៍។ បន្តិចម្តងៗ ការខិតខំប្រឹងប្រែងរបស់គាត់បានផលដល់គ្រួសាររបស់គាត់ មានអាហារគ្រប់គ្រាន់ ហើយគាត់រកបានបន្ថែមបានពី ១៥០ ទៅ ២០០ ដុល្លារក្នុងមួយខែដោយការលក់ផលិតផលកសិកម្មរបស់គាត់។ ប្រាក់ចំណូលនេះ បានអនុញ្ញាតឱ្យគាត់បញ្ជូនកូនរបស់គាត់ទៅសាលារៀនវិញ។

ក្រៅពីការលើកកម្ពស់ជីវភាពផ្ទាល់ខ្លួន លោក ចាន់រស្មី បានចែករំលែកចំណេះដឹងរបស់ខ្លួនជាមួយកសិករផ្សេងទៀត ដោយលើកទឹកចិត្តពួកគេឱ្យទទួលយកការអនុវត្តកាន់តែប្រសើរ។ ផ្នត់គំនិត និងអាកប្បកិរិយារបស់គាត់បានផ្លាស់ប្តូរ ហើយគ្រួសាររបស់គាត់ឥឡូវនេះទទួលបានស្ថេរភាព និងក្តីសង្ឃឹមកាន់តែច្រើនសម្រាប់អនាគត។ គាត់និយាយថា អង្គការ អេហ្វ អេក មិនត្រឹមតែផ្តល់ជំនួយដល់យើងប៉ុណ្ណោះទេ ពួកគេបានបង្រៀនយើងពីរបៀបដាំបន្លែ និងចិញ្ចឹមសត្វ។ ឥឡូវនេះ ខ្ញុំចែករំលែកអ្វីដែលខ្ញុំបានរៀនជាមួយអ្នកជិតខាងរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍សប្បាយណាស់ដែលឃើញសហគមន៍របស់យើងរីកចម្រើនជាមួយគ្នា" ។

"ឥឡូវនេះ ខ្ញុំមានមោទនភាពក្នុងការក្លាយជាកសិករគំរូ ហើយអ្នកជិតខាងរបស់ខ្ញុំអាចពឹងពាក់បាន ហើយឃើញកូនរបស់ខ្ញុំមានសុខភាពល្អ និងសប្បាយរីករាយ បានជំរុញទឹកចិត្តខ្ញុំឱ្យបន្តការសិក្សា និងចែករំលែក។"

លោក ចាន់ រស្មី កសិករគំរូ

៦.២ សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត

គោលបំណង៖ លើកកម្ពស់សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ម្តាយ អ្នកថែទាំ កុមារ និងមនុស្សពេញវ័យ ដើម្បីសម្រេចការអភិវឌ្ឍសក្តានុពលពេញលេញរបស់ពួកគេ តាមរយៈការទទួលបានអាហារចម្រុះមុខ អាហារូបត្ថម្ភ ការថែទាំសុខភាព និងទឹកស្អាត និងអនាម័យ។

លទ្ធផលរំពឹងទុកទី១៖

ធ្វើអោយប្រសើរឡើងនូវសុខភាពម្តាយ ទារក និងកុមារតូចអាយុក្រោម ២ឆ្នាំ

លទ្ធផលរំពឹងទុកទី២៖

ធ្វើអោយមានប្រសើរឡើងនូវចំណេះដឹង និងការអនុវត្តរបស់ម្តាយ ឬ អ្នកថែទាំស្តីពីអាហារូបត្ថម្ភរបស់ទារក កុមារតូច ការថែទាំ និង ការបញ្ចុកអាហារ

លទ្ធផលរំពឹងទុកទី៣៖

ធ្វើអោយមានភាពប្រសើរឡើងនូវចំណេះដឹង ឥរិយាបថ និងការអនុវត្តទៅលើការប្រើប្រាស់បង្គន់ដែលមានការកែលំអរ ប្រភពទឹកកែលំអរ និងអនាម័យក្នុងមូលដ្ឋាន

លទ្ធផលរំពឹងទុកទី៤៖

ធ្វើអោយប្រសើរឡើងនូវប្រភពទឹកកែលំអ ការប្រើប្រាស់បង្គន់ដែល មានការកែលំអ និងអនាម័យប្រសើរ នៅមណ្ឌលសុខភាព ឬគ្រឹះស្ថានសុខភាពក្នុងតំបន់គោលដៅ

លទ្ធផលរំពឹងទុកទី៥៖

ធ្វើអោយមានភាពប្រសើរឡើងនូវការទទួលបានទឹកសុវត្ថិភាព ការប្រើប្រាស់បង្គន់ និងអនាម័យក្នុងមូលដ្ឋានសិក្សា

ក្រុមគោលដៅដែលយើងធ្វើការជាមួយ៖

<u>សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត</u>

- ១៨ មណ្ឌលសុខភាព
- ១៨៤ សមាជិកក្រុមទ្រទ្រង់សុខភាពភូមិ
- ៧៥០ ក្រុមក្តីសង្ឃឹមសុខភាព

<u>ទឹកស្អាត និងអនាម័យ</u>

- ៧១ ក្រុមគណៈកម្មាធិការបានចងក្រងជាគណៈកម្មាការទឹកស្អាត និងអនាម័យ
- ១៩៩ សមាជិកគណៈកម្មាការអភិវឌ្ឍន៍ភូមិ
- ៨៩ សាលារៀនបឋមសិក្សា

<u>សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត</u>

- ៧២% កុមារអាយុ ០-៦ ខែបានបំបៅទឹកដោះម្ដាយតែគត់ក្នុងរយៈពេល៦ខែ
- ៤៧.២% កុមារអាយុ ៦-២៣ ខែទទួលបានរបបអាហារចម្រុះ
- ៥.៦% កុមារអាយុ ០-២៣ ខែស្ថិតក្នុងស្ថានភាពកង្វះអាហារូបត្ថម្ភស្រួចស្រាវ (ស្គមស្គាំង) ដោយការវាស់ពាក់កណ្ដាលដើមដៃ
- ២០.៣% កុមារអាយុ ០-២៣ ខែស្ថិតក្នុងស្ថានភាពកង្វះអាហារូបត្ថម្ភមធ្យម
- ៨៤% ស្ត្រីដែលមានកូនអាយុក្រោម២ឆ្នាំ បានបរិភោគរបបអាហារចម្រុះ ៥មុខក្នុងចំណោម១០មុខនៃក្រុមអាហារ ក្នុងរយៈពេល ២៤ ម៉ោងមុន
- ៩២% ស្ត្រីដែលមានកូនអាយុ ០-២៣ ខែបានពិនិត្យផ្ទៃពោះមុនសម្រាល ៤ដង ឬលើសក្នុងពេលមានផ្ទៃពោះ
- ៨៦.៨% កុមារអាយុ ១២-២៤ ខែ បានចាក់វ៉ាក់សាំងការពារជំងឺគ្រប់ចំនួន
- ១ ១៣៥ នាក់ (ស្ត្រី ១០២១) បានចូលរួមវគ្គអប់រំសុខភាពតាមសហគមន៍អំពីសុខភាព អាហារូបត្ថម្ភ និងទឹកស្អាត និងអនាម័យ។
- ២ ២៦០ ស្ត្រីជាម្ដាយ អ្នកថែទាំកុមារបានចូលរួមវគ្គធ្វើបបរអាហារូបត្ថម្ភបង្ហាញ
- ២ ២៦០ កុមារអាយុក្រោម២ឆ្នាំ (ក្មេងស្រី ១ ២២០)បានចូលរួមក្នុងការវាស់ថ្លឹង និងតាមដានការលូតលាស់
- ៧១៧ បុរសបានចូលរួមក្នុងសកម្មភាពអាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារ។

<u>ទឹកស្អាត និងអនាម័យ</u>

- ៦២.១% ខ្នងផ្ទះនៅជនបទទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋាន
- ៧៩.៥% ខ្នងផ្ទះនៅជនបទមានបង្គន់អនាម័យកម្រិតមូលដ្ឋាន
- ៩២% ខ្នងផ្ទះនៅជនបទទទួលបានសេវាអនាម័យកម្រិតមូលដ្ឋាន
- ៨៥.៥% ស្ត្រីដែលមានកូនអាយុ ០-២៣ខែទទួលបានការគ្រប់គ្រងជំងឺ និងព្យាបាលជំងឺរាកបានត្រឹមត្រូវនៅពេលដែលពួកគាត់មានជំងឺរាក
- ៧៥% មណ្ឌលសុខភាពក្នុងតំបន់គោលដៅមានទឹកស្អាតប្រើប្រាស់ជាមូលដ្ឋាន
- ១០០% មណ្ឌលសុខភាពក្នុងតំបន់គោលដៅមានកន្លែងលាងដៃ
- ៧៤.២% សាលារៀនក្នុងតំបន់គោលដៅមានប្រភពទឹកបានកែលម្អប្រើប្រាស់ជាមូលដ្ឋាន
- ៨២% នៃសាលាក្នុងតំបន់គោលដៅមានបង្គន់អនាម័យមានការកែលម្អ
- ៨ អណ្ដូងទឹកបានសាងសង់រួចរាល់នៅក្នុងសហគមន៍
- ៦ ស្ថានីយ៍ទឹកខ្នាតតូចបានសាងសង់ក្នុងនោះមាន ៣ស្ថានីយ៍ក្នុងសាលាបឋមសិក្សា និង ៣ស្ថានីយ៍ស្ថិតក្នុងមណ្ឌលសុខភាព។
- ៦ បង្គន់អនាម័យដែលប្រកបដោយបរិយាបន្ន ដែលក្នុងនោះរួមមាន ៣បង្គន់អនាម័យនៅសាលាបឋម និង ៣បង្គន់អនាម័យនៅមណ្ឌលសុខភាព
- ៣ ៨៨៩ កញ្ចប់សម្ភារៈអនាម័យ រួមមាន ៣ ៨៤២ កញ្ចប់ ដល់គ្រួសារ និង ៤៧កញ្ចប់ទៅសាលាបឋមសិក្សា។
- ២៧៦ ធុងទឹកផ្ដល់ជូនទៅគ្រួសារដែលងាយរងគ្រោះ
- ៧៣៨ ធុងចម្រោះទឹក រួមមាន ៤៨៨ សម្រាប់គ្រួសារដែលងាយរងគ្រោះ និង ២៥០ សម្រាប់ជនភៀសសឹក
- ៣៥១ គ្រួសារទទួលបានសម្ភារៈគ្រឿងក្រោមសម្រាប់សាងសង់បង្គន់អនាម័យ ដែលចំនួន២៨១ សម្រាប់គ្រួសារក្រីក្រ (ក្រ១ និង ក្រ២) និង ៧០ សម្រាប់ជំរំជនភៀសសឹក។

ការប្រែក្លាយពីម្តាយធម្មតាម្នាក់ ទៅជាម្តាយគំរូ និងជាអ្នកនាំការផ្លាស់ប្តូរ

អ្នកស្រី នួន ផល្លី អាយុ ៣០ ឆ្នាំ រស់នៅភូមិព្រះក្រាល ស្រុកត្រពាំងប្រាសាទ ជាសមាជិកក្រុមទ្រទ្រង់សុខភាព និងជាដៃគូអភិវឌ្ឍសហគមន៍ ។ មុនពេលក្លាយជាអ្នកស្ម័គ្រចិត្តសុខភាពជាមួយ អង្គការ អេហ្វ អេក កម្ពុជា លោកស្រីមានភាពខ្មាស់អៀន ខ្វះទំនុកចិត្តលើខ្លួនឯងក្នុងការនិយាយ លើកមតិយោបល់ក្នុងចំណោមមនុស្សម្នា និងភ័យខ្លាចក្នុងការប្រឈមមុខនឹងបញ្ហានៅក្នុងសហគមន៍។ តាមរយៈការបណ្តុះបណ្តាលរបស់អង្គការ អេហ្វ អេក កម្ពុជា អ្នកស្រីផល្លីបានចូលរួមវគ្គបណ្តុះបណ្តាល ព្រមជាមួយជំនាញអនុវត្តជាក់ស្តែងក្នុងការថែទាំកូន និងគ្រួសារ។ អ្នកស្រីបានរៀនពីចំណេះដឹងអំពីការថែទាំក្នុងពេលមានផ្ទៃពោះ ការថែទាំក្រោយសម្រាល ការថែទាំកុមារពេលឈឺ និងការចិញ្ចឹម និងផ្តល់អាហារដែលសមស្របតាមអាយុរបស់កុមារ។ លើសពីនេះ អ្នកស្រីក៏បានយល់ដឹងបន្ថែមលើការអនុវត្តអនាម័យផ្ទាល់ខ្លួន ការបន្សុទ្ធទឹកមុនពេលផឹក ការបោះចោលសំរាម ការលាងដៃត្រឹមត្រូវជាមួយសាប៊ូ និងទឹកលំហូរ។

ចំណេះដឹងទាំងនេះបានផ្លាស់ប្តូរអ្នកស្រីទាំងទំនុកចិត្ត និងតួនាទីរបស់អ្នកស្រីក្នុងសហគមន៍។ អ្នកស្រីផល្លីឥឡូវនេះបានចូលរួមសកម្មក្នុងការអប់រំ និងចែករំលែកចំណេះដឹងទៅអ្នកជិតខាងអំពីការអនុវត្តអាហារូបត្ថម្ភល្អ អនាម័យជាប្រចាំថ្ងៃ ការលើកទឹកចិត្តគ្រួសារដែលមិនមានបង្គន់ឱ្យសាងសង់បង្គន់ដែលសាមញ្ញនិងតម្លៃទាប ។ អ្នកស្រីបានលើកទឹកចិត្តដល់ម៉ែៗ និងអ្នកថែទាំកុមារឱ្យស្វែងរកសេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ការត្រួតពិនិត្យ និងតាមដានស្ថានភាពអាហារូបត្ថម្ភកូន។

សំខាន់ជាងនេះ អ្នកស្រីក៏បានអនុវត្តចំណេះដឹងទាំងនេះក្នុងជីវិតគ្រួសាររបស់អ្នកស្រីផ្ទាល់ ជាពិសេសចំពោះកូនប្រុសរបស់អ្នកស្រីដែលមានអាយុ ១៨ ខែ។ ក្នុងពេលមានផ្ទៃពោះ អ្នកស្រីបានអនុវត្តតាមការណែនាំរបស់គ្រូពេទ្យយ៉ាងម៉ត់ចត់ សម្រាលកូននៅមណ្ឌលសុខភាពដែលជិតផ្ទះ និងបានធ្វើការត្រួតពិនិត្យនិងតាមដានសុខភាពក្រោយសម្រាល។ អ្នកស្រីបានបំបៅកូនដោយទឹកដោះម្តាយតែប៉ុណ្ណោះក្នុងរយៈពេល ៦ ខែដំបូង និងបន្តរហូតដល់បច្ចុប្បន្ន ដើម្បីធានាអាហារូបត្ថម្ភល្អ និងការការពារការឆ្លងជំងឺ។

អ្នកស្រីមានការប្តេជ្ញាចិត្តដើម្បីក្លាយជាជនគំរូសម្រាប់អ្នកម្តាយផ្សេងទៀត និងសហគមន៍ទាំងមូល។ ភាពផ្លាស់ប្តូររបស់អ្នកស្រីបានបង្ហាញថា ចំណេះដឹង និងទំនុកចិត្តអាចបង្កើតឥទ្ធិពល និងផលជះជាវិជ្ជមាន ដែលផ្តើមចេញពីការអនុវត្តជាមួយក្រុមគ្រួសាររបស់អ្នកស្រីផ្ទាល់ និងបន្តទៅដល់សហគមន៍ទាំងមូលដែលផ្តោតលើអនាម័យ និងអាហារូបត្ថម្ភល្អប្រសើរ។

"ឥឡូវនេះខ្ញុំមានទំនុកចិត្ត និងអាចអប់រំអ្នកជិតខាង និងសហគមន៍អំពីការថែទាំសុខភាព និងអាហារូបត្ថម្ភល្អ និងអនុវត្តអនាម័យមូលដ្ឋាន។ ខ្ញុំមានមោទនភាព និងមានអារម្មណ៍ថាបានចូលរួមជាចំណែកក្នុងការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ និងអនាម័យក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព និងប្រសើរជាងមុន។"

—លោកស្រី នួន ផល្លី   អ្នកស្ម័គ្រចិត្តសហគមន៍

៦.៣ លទ្ធផលសិក្សាល្អប្រសើរ

គោលបំណង៖ លទ្ធផលសិក្សាល្អប្រសើរ (កម្មវិធីអប់រំ) ធ្វើការដើម្បីធានាថាកុមារ ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត មានលទ្ធភាពទទួលបានការអប់រំស្មើៗគ្នាប្រកបដោយគុណភាព ដែលអ្នកអាណាព្យាបាល សាលារៀន និងសហគមន៍ បានចូលរួមគាំទ្រយ៉ាងសកម្មលើដំណើរការរៀនសូត្រ។

លទ្ធផលរំពឹងទុកទី១៖
បង្កើនការកៀរគរកុមារគ្រប់អាយុចុះឈ្មោះចូលរៀនទាន់ពេលវេលា ទាំងមត្តេយ្យសិក្សា និងបឋមសិក្សា ប្រកប ដោយគុណភាព និង សមធម៌

លទ្ធផលរំពឹងទុកទី២៖
លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងអ្នកដឹកនាំសាលារៀន ដើម្បីឱ្យការបង្រៀនមានគុណភាព

លទ្ធផលរំពឹងទុកទី១៖
ការពង្រឹងក្រុមអ្នកស្ម័គ្រចិត្តសហគមន៍ដើម្បីគាំទ្រដល់ការរៀនសូត្ររបស់កុមារ

លទ្ធផលរំពឹងទុកទី១៖
អភិវឌ្ឍយុវជន ដើម្បីលើកកម្ពស់លទ្ធផលសិក្សាល្អប្រសើររបស់កុមារនៅតាមសហគមន៍

ក្រុមគោលដៅដែលយើងធ្វើការជាមួយ៖

- ១២២ សាលាបឋមសិក្សា
- ៧០ សាលាមត្តេយ្យសិក្សារដ្ឋ
- ៤០ មត្តេយ្យសិក្សាសហគមន៍
- ៧៦ ក្លឹបកុមារ
- ១១១២ គ្រូបង្រៀន
- ៧៧៦ ក្រុមអ្នកស្ម័គ្រចិត្តសហគមន៍ដើម្បីការអប់រំ
- ៣៩០៤ សមាជិកអ្នកជិតខាង (អ្នកថែទាំកុមារ) 
- ៤១៩ យុវជន
- ២៦៧៩៨ កុមារ

លទ្ធផលសិក្សាល្អប្រសើរ

- ៤៦.៨% អ្នកថែទាំកុមារអាយុ ០-៦ឆ្នាំ ដែលបានចូលរួមក្នុងសកម្មភាពចំនួន ៤ ឬច្រើនជាងនេះ ដើម្បីលើកកម្ពស់ការរៀនសូត្រក្នុងរយៈពេល ៣ ថ្ងៃចុងក្រោយ
- ២៧% អ្នកថែទាំកុមារដែលរៀននៅថ្នាក់ទី ១-៣ ដែលមានសកម្មភាពសិក្សាជាមួយកូនបាន៤ដង ឬច្រើន ជាងនេះ ក្នុងរយៈពេល ៣ ថ្ងៃចុងក្រោយ
- ៥៧% កុមារអាយុ ៣-៦ ឆ្នាំនៅក្នុងគ្រួសារដែលបានចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សា។
- ៩២% កុមារអាយុ ៦-៩ ឆ្នាំនៅក្នុងគ្រួសារដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា
- ៤៥% បណ្ណាល័យសាលាដែលគាំទ្រដោយគម្រោងមានដំណើរការល្អ
- ៥៨% សិស្សថ្នាក់ដំបូង បានតេស្តជាប់កម្រិតនៃអំណាន និងគណិតវិទ្យានៅចុងឆ្នាំ
- ៥៥% ក្លឹបកុមារដំណើរការល្អ ក្នុងការគាំទ្រដល់ការរៀនសូត្ររបស់កុមារនៅក្នុងសហគមន៍
- ៦៣% គ្រូបង្រៀនបានអភិវឌ្ឍសមត្ថភាពបង្រៀនរបស់ខ្លួនបានល្អប្រសើរ ដោយប្រើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព
- ១១៨ (ស្រី ១១៨នាក់) គ្រូមត្តេយ្យសិក្សា ត្រូវបានបណ្តុះបណ្តាលលើជំនាញបង្រៀនតាមរយៈការលេង ដើម្បីគាំទ្រការរៀនអក្សរ និងគណិតវិទ្យាមុនចូលរៀននៅបឋមសិក្សា
- ២០៦ (ស្រី ១៣៤នាក់) គ្រូបង្រៀនថ្នាក់ទី ១-៣ ត្រូវបានបណ្តុះបណ្តាលលើយុទ្ធសាស្ត្របង្រៀនសម្រាប់ការអានសរសេរ និងគណិតវិទ្យា
- ១២១ (ស្រី ០៧នាក់) ថ្នាក់ដឹកនាំសាលា ត្រូវបានបណ្តុះបណ្តាលអំពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល
- ៣៦ សាលាមត្តេយ្យសិក្សាសហគមន៍ត្រូវបានគាំទ្រ ដើម្បីកែលម្អលទ្ធភាពសិក្សា និងការត្រៀមខ្លួនសម្រាប់ថ្នាក់ទី១
- ២៥៦ (ស្រី ១៥៩នាក់) គ្រូបង្រៀន ត្រូវបានតម្រង់ទិសលើគោលនយោបាយការពារកុមារនៅក្នុងសាលារៀន
- ៨៣ (ស្រី ៥២នាក់) បណ្ណារក្សនិងអ្នកដឹកនាំសាលា ត្រូវបានបណ្តុះបណ្តាលអំពីការគ្រប់គ្រងបណ្ណាល័យឱ្យដំណើរការល្អ។
- ១ ១៣៣ (ស្រី ៦៩៤នាក់) កុមារដែលងាយរងគ្រោះប្រឈមនឹងការបោះបង់ការសិក្សា បានទទួលសម្ភារៈសិក្សា
- ៧៧៦ សមាជិកជាស្ត្រីនៃក្រុមអ្នកស្ម័គ្រចិត្តសម្រាប់ការអប់រំ និងអ្នកស្ម័គ្រចិត្តដៃគូសហគមន៍ត្រូវបានបណ្តុះបណ្តាលលើការជំរុញលើកទឹកចិត្ត និងការត្រៀមខ្លួនដើម្បីចូលរៀនសម្រាប់កុមារ ការទទួលបានជោគជ័យនៅថ្នាក់ដំបូង និងជំនាញសម្របសម្រួល។
- ៣ ៩០៤ អ្នកថែទាំកុមារក្នុងសហគមន៍ បានចូលរួមក្នុងវគ្គសិក្សាស្តីពីការជួយគាំទ្រការសិក្សារបស់កូនៗនៅផ្ទះ។

ការបង្កើនក្តីស្រឡាញ់ចំពោះការអាន នៅក្នុងសាលាបឋមសិក្សាក្តុល

សាលាបឋមសិក្សាក្តុល ស្ថិតនៅក្នុងស្រុកបន្ទាយអំពិល ជិតព្រំដែនកម្ពុជា-ថៃ ដែលគ្រួសារភាគច្រើនតែងតែប្រឈមនឹងការធ្វើចំណាកស្រុក ការងារតាមរដូវកាល និងភាពតានតឹងនៅតាមព្រំដែននាពេលថ្មីៗនេះ។ បញ្ហាទាំងនេះធ្វើឱ្យកុមារមានការលំបាកក្នុងការចូលរៀន និងអភិវឌ្ឍជំនាញអានឱ្យបានរឹងមាំ។ តាមរយៈគម្រោង «លទ្ធផលសិក្សាល្អប្រសើរ» របស់អង្គការ អេហ្វ អេក កម្ពុជា សាលាបឋមសិក្សាក្តុលទទួលបានការគាំទ្រទៅលើការលើកកម្ពស់ផ្នែកអំណាន និងគណិតវិទ្យាសម្រាប់ថ្នាក់ដំបូង តាមរយៈការបណ្តុះបណ្តាលគ្រូ និងការកែលម្អបណ្ណាល័យ។

លោកគ្រូ អ្នកគ្រូបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល សម្រាប់ការបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានៅកម្រិតថ្នាក់ដំបូង ការប្រើប្រាស់សៀវភៅរឿងនិទាន សកម្មភាពជាក្រុម និងល្បែងកម្សាន្ត ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានភាពទាក់ទាញ។ បណ្ណាល័យក្នុងសាលាត្រូវបានកែលម្អឡើងវិញ ដោយបន្ថែមធ្នើរដាក់សៀវភៅថ្មីៗ និងសៀវភៅរឿងនិទានជាភាសាខ្មែរជាច្រើនប្រភេទ និងការរៀបចំឱ្យមានកន្លែងសម្រាប់កុមារអានសៀវភៅ។ ការចុះបង្វឹកផ្ទាល់បានជួយលើកទឹកចិត្តគ្រូបង្រៀនឱ្យអនុវត្តនូវវិធីសាស្ត្របង្រៀនថ្មីៗ។ លើសពីនេះផងដែរ ថ្នាក់ដឹកនាំសាលាក៏ដូចជាការិយាល័យអប់រំស្រុក បានសហការគ្នាជាមួយអង្គការ អេហ្វ អេក កម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់បណ្ណាល័យ និងការអនុវត្តការអានជាប្រចាំ។

លោក ស្មាស់ សារុន ជាគ្រូបង្រៀនម្នាក់នៅសាលាបឋមសិក្សាក្តុល បានចែករំលែកថា៖

«ចាប់តាំងពីគម្រោងនេះបានពង្រឹងការអាននៅក្នុងសាលារៀនរបស់យើង ខ្ញុំបានរៀនវិធីសាស្ត្របង្រៀនថ្មីៗ ហើយបណ្ណាល័យរបស់យើងឥឡូវនេះមានសៀវភៅរឿងនិទានល្អៗជាច្រើន។ ទោះបីជាមានបញ្ហាប្រឈមក្នុងសហគមន៍ក៏ដោយ ខ្ញុំមើលឃើញពីភាពប្រសើរឡើងយ៉ាងពិតប្រាកដនៅក្នុងការអានរបស់សិស្សរបស់ខ្ញុំ។ មេរៀនរបស់ខ្ញុំកាន់តែមានភាពប្រទាក់គ្នា ហើយកុមារកាន់តែមានទំនុកចិត្តក្នុងការអានឮៗ និងចូលរួមសកម្មភាពផ្សេងៗទៀត។ ខ្ញុំពិតជាមានមោទនភាពដែលឃើញពួកគេមានក្តីស្រឡាញ់ក្នុងការសិក្សារៀនសូត្រ»។

បច្ចុប្បន្ននេះ កុមារនៅសាលាបឋមសិក្សាក្តុល មានលទ្ធភាពចូលទៅអានសៀវភៅកាន់តែច្រើន ហើយពួកគេចូលរួមសកម្មភាពក្នុងការរៀនកាន់តែច្រើនផងដែរ ដូច្នេះលោកគ្រូអ្នកគ្រូក៏មានទឹកចិត្តក្នុងការបង្រៀនអំណាន។ ទោះបីជាកំពុងតែស្ថិតនៅក្នុងស្ថានភាពផុយស្រួយ តែការបង្រៀនកាន់តែមោះមុត ហើយការគាំទ្រសម្ភារៈសិក្សាដែលសមរម្យបែប និងបរិយាកាសគាំទ្រកំពុងតែជួយជំរុញការផ្លាស់ប្រែអ្នកដែលអាននៅមានកម្រិត ទៅជាអ្នកអានដែលមានទំនុកចិត្ត។

—លោក ស្មាស់ សារុន ជាគ្រូបង្រៀនម្នាក់

៦.៤ សកម្មភាពមនុស្សធម៌

បន្ទាប់ពីមានបញ្ហាជម្លោះព្រំដែនក្នុងខែកក្កដា ២០២៥មក អង្គការ អេហ្វ អេក កម្ពុជា បានធ្វើការសិក្សាពីតម្រូវការបន្ទាន់របស់ជនភៀសសឹក ហើយបានឆ្លើយតបជាជំនួយមនុស្សធម៌ បន្ថែមលើកម្មវិធីស្នូលដែលកំពុងអនុវត្តនៅតំបន់គោលដៅ។ ដោយមានការសម្របសម្រួលជាមួយអាជ្ញាមូលដ្ឋាន និងដៃគូមនុស្សធម៌ យើងបានផ្តល់ជំនួយលើផ្នែក ទឹកស្អាត និងអនាម័យ អាហារ ជម្រក និងការអប់រំ។

១. ទឹកស្អាត និងអនាម័យ
៧ ២៩៩ គ្រួសារ

២. ជំនួយអាហារបន្ទាន់
៨៩២ គ្រួសារ

៣. ជំនួយជាជម្រកបន្ទាន់
២១៥ គ្រួសារ

៤. ការអប់រំក្នុងគ្រាអាសន្ន
៣ ទីតាំងកុមារមេត្រីដែលមានសម្ភារៈសម្រាប់កុមាររៀន

៧. គម្រោងផ្តួចផ្តើមថ្មីៗ

៧.១ គម្រោងទឹកដើម្បីសុខភាព (តំបន់អភិវឌ្ឍន៍ស្រុកត្រពាំងប្រាសាទ៣)

គោលបំណង៖ បង្កើនការប្រើប្រាស់ប្រភពទឹកដែលបានកែលម្អ និងបង្គន់អនាម័យដែលប្រកបដោយបរិយាបន្នសម្រាប់ទាំងអស់គ្នា។

លទ្ធផលសម្រេចបានសំខាន់ៗ៖

- ១ ស្ថានីយទឹកខ្នាតតូច ដែលរួមមានអណ្តូងខួង ប្រព័ន្ធសូឡា និងស៊ីទែនទឹកចំណុះ ៣ ០០០ លីត្រ
- ៧ បង្គន់អនាម័យដែលប្រកបដោយបរិយាបន្ន
- ២ ឡដុតសំរាមត្រូវបានដំឡើងសម្រាប់គ្រប់គ្រងសំណល់ក្នុងមណ្ឌលសុខភាព
- ២៨ គណៈកម្មាការគ្រប់គ្រងនិងថែទាំអនាម័យបានទទួលការបណ្តុះបណ្តាលស្តីពីវិធានការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ(HAIs) បច្ចេកទេសសាងសង់ និងការថែទាំ។
- ១៣៩០ ផ្ទាំងនៃរូបភាពអប់រំសុខភាពស្តីពីវិធានការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ។
- ១០០% មណ្ឌលសុខភាពក្នុងតំបន់មានបង្គន់អនាម័យប្រកបដោយបរិយាបន្នប្រើប្រាស់
- ៧៥% មណ្ឌលសុខភាពក្នុងតំបន់មានប្រភពទឹកកែលម្អប្រើប្រាស់។

៧.២ គម្រោងកសាងសមត្ថភាពធន់នឹងការប្រែប្រួលអាកាសធាតុតាមរយៈកម្មវិធីទឹកស្អាត និងអនាម័យ និងកម្មវិធីមុខរបរចិញ្ចឹមជីវិតប្រកបដោយចីរភាព នៅក្នុងស្រុកពួក

គោលបំណង៖ កសាងសហគមន៍ដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ នៅស្រុកពួក ដោយរួមបញ្ចូលការអនុវត្តកម្មវិធី អនាម័យ ទឹកស្អាត (WASH) និងអនុវត្តន៍កសិកម្មប្រកបដោយចីរភាព ដើម្បីលើកកម្ពស់សុខភាពការរស់នៅ និងការត្រៀមខ្លួនជាស្រេចទប់ទល់នឹងគ្រោះមហន្តរាយ។

លទ្ធផលសម្រេចបានសំខាន់ៗ៖

- ១០៨ កសិករ (ស្រី ៩៥) ទទួលការបណ្តុះបណ្តាលអំពីគោលការណ៍កសិកម្មឆ្លាតវៃប្រកបដោយភាពធន់ទ្រាំនឹងអាកាសធាតុ បច្ចេកទេសសួនដំណាំធន់ទ្រាំនឹងអាកាសធាតុ សួនដំណាំសុខភាពតាមផ្ទះ និងការអនុវត្តការដាំដំណាំចម្រុះ
- ៥ ស្ថានីយ៍ទឹកខ្នាតតូចបានសាងសង់រួចក្នុងភូមិគោលដៅ
- ១០៥ ឡដុតទែនទឹកសម្រាប់ត្រងទឹកភ្លៀងបានចែកជូនដល់គ្រួសារក្រ១ និងក្រ២ ព្រមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ

១០៥ កសិករ(ស្ត្រី៩១នាក់) បានទទួលការបណ្ដុះបណ្ដាលអំពីបច្ចេកទេសចិញ្ចឹមសត្វបក្សី

៦៣ សមាជិក (ស្រី១៦នាក់) គណៈកម្មាធិការការគ្រប់គ្រងមហន្តរាយថ្នាក់ឃុំ (CCDM) បានចូលរួមប្រជុំដើម្បីកំណត់បញ្ហាប្រឈម សមត្ថភាព និងការយល់ដឹងអំពីយន្តការ និងនីតិវិធីរាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងមហន្តរាយថ្នាក់ឃុំ (CCDM)

៧៧៧ អ្នកចូលរួម(ស្រី ៦៧៧នាក់) ដែលមានគ្រូបង្រៀន សិស្ស និងសហគមន៍ បានផ្សព្វផ្សាយការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ការត្រៀមខ្លួនការបង្ការគ្រោះមហន្តរាយ និងយុទ្ធសាស្ត្រទប់ស្កាត់។

៧.៣ គម្រោងលើកកម្ពស់ការសិក្សា តាមរយៈបច្ចេកវិទ្យា

គោលបំណង៖ ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្កើនលទ្ធផលសិក្សារបស់កុមារនៅកម្រិតថ្នាក់ដំបូង។

- ការធ្វើតេស្តអំណាន (EGRA) និង គណិតវិទ្យាថ្នាក់ដំបូង (EGMA) ត្រូវប្រើសម្រាប់វាស់វែងលទ្ធផលសិក្សារបស់កុមារថ្នាក់ទី១ ដល់ទី៣។
- ជារួម លទ្ធផលបង្ហាញថា កុមារទទួលបានលទ្ធផលសិក្សាកើនឡើងគួរកត់សម្គាល់ បើប្រៀបធៀបរវាងទិន្នន័យដើមគ្រា និងលទ្ធផលចុងគ្រា ទៅតាមសមត្ថភាពលើសមាសភាគអំណាន និងគណិតវិទ្យា។





៧.៤ គម្រោងតៀរគេរពួកជំនុំសម្រាប់ការបំផ្លាស់បំប្រែសហគមន៍ (MCCT)

គោលដៅ៖ កុមារងាយរងគ្រោះទទួលបាននូវការគាំទ្រនៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេដែលក្នុងនោះក្រុមជំនឿបានចូលរួមគាំទ្រដល់ការផ្លាស់ប្តូរក្នុងសហគមន៍ និងធ្វើជាគំរូឈានមុខក្នុងការបញ្ឈប់រាល់ការអនុវត្តដែលបង្កគ្រោះថ្នាក់នានាក្នុងការដាក់វិន័យ និងការចិញ្ចឹមបីបាច់កុមារ។

លទ្ធផលសម្រេចបានសំខាន់ៗ៖

- **១៨** ពួកជំនុំជាដៃគូថ្មីដែលរួមចំណែកក្នុងការផ្លាស់ប្រែសហគមន៍ នៅក្រុងសំរោង ចុងកាល បន្ទាយអំពិល និងស្រុកពួក
- **១០** គ្រួសារក្រីក្រក្នុងពួកជំនុំ ទទួលការគាំទ្រជាសម្ភារៈធ្វើបង្គន់
- **៩៧** អ្នកដឹកនាំពួកជំនុំ និងអាជ្ញាធរមូលដ្ឋាន (ស្រី៥៨នាក់) បង្កើនចំណេះដឹង និងផ្សព្វផ្សាយបន្តដល់សហគមន៍អំពី សិទ្ធិកុមារ ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ការរៀបចំទស្សនៈវិស័យ របៀបជួយអ្នកដទៃ ឫសគល់នៃភាពក្រីក្រ ការធ្វើផែនការ ទម្រង់ផ្សេងៗនៃការរំលោភបំពាន និងចំណាកស្រុកដោយសុវត្ថិភាព
- **១ ០០១** ប្រជាជន (ស្រី ៦០៤នាក់) ក្នុងសហគមន៍មានការយល់ដឹងអំពីសិទ្ធិកុមារ ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ការរៀបចំទស្សនៈវិស័យ របៀបជួយអ្នកដទៃ ឫសគល់នៃភាពក្រីក្រ ការធ្វើផែនការ ទម្រង់ផ្សេងៗនៃការរំលោភបំពាន និងចំណាកស្រុកដោយសុវត្ថិភាព
- **១៧** ក្លឹបកុមារត្រូវបានរៀបចំ និងចេះដឹកនាំសកម្មភាពរៀនសូត្រជាមួយកុមារនៅក្នុងសហគមន៍។

៨. ការកសាងបណ្តាញការងារ និងភាពជាដៃគូ

អង្គការ អេហ្វ អេក កម្ពុជា បានចូលរួមក្នុងក្រុមការងារបច្ចេកទេសជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្របគ្នានឹងជំនាញរបស់អង្គភាព ដើម្បីរួមចំណែកជាធាតុចូលបច្ចេកទេស សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ និងការចែករំលែកជំនាញ និងបទពិសោធល្អនានា។

ការកសាងទ្រព្យសកម្ម

- ក្រុមបច្ចេកទេស វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSN)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- នាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប និងឧត្តរមានជ័យ

សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត និងអនាម័យ និងទឹកស្អាត

- យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២០២៥-២០៣០) តាមរយៈក្រុមការងារសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ (SUN-CSA)
- យុទ្ធនាការទិវាសប្តាហ៍ពិភពលោកបំបៅដោះម្តាយ ឆ្នាំ ២០២៥ ជាមួយក្រុមក្រុមប្រឹក្សាបច្ចេកទេសអាហារូបត្ថម្ភថ្នាក់ជាតិ
- កិច្ចប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាបច្ចេកទេសថ្នាក់ខេត្តក្នុងខេត្តសៀមរាប និងឧត្តរមានជ័យ
- បានចូលរួមប្រជុំបច្ចេកទេសប្រចាំខែរបស់ ក្រុមប្រឹក្សាបច្ចេកទេសលើកកម្ពស់សុខភាពថ្នាក់ជាតិជាមួយមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព
- ចូលរួម និងគាំទ្រក្នុងពិធីអបអរសាទរខេត្តឧត្តរមានជ័យបានទទួលជ័យលាភីជាខេត្តបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល (ODF)
- ក្រុមប្រឹក្សាទឹកស្អាត និងអនាម័យ (WatSAN) និង ក្រុមប្រឹក្សាអនាម័យ និងសុខភាពជនបទ (RuSH)
- ក្រុមស្នូលក្នុងការរៀបចំផែនការអនុវត្តជាតិ ទឹកស្អាត និងអនាម័យយ ដំណាក់កាលទី៣ (ឆ្នាំ ២០២៥–២០២៣៣)
- ជាសមាជិកសកម្មនៃក្រុមបណ្តាញអាហារូបត្ថម្ភ Scaling Up Nutrition Civil Society Alliance (SUN-CSA) គណៈកម្មាការសម្របសម្រួលសុខភាព (HACC) វេទិកាឆ្លើយតបមនុស្សធម៌ (HRF)។

លទ្ធផលសិក្សាល្អប្រសើរ

- ក្រុមការងារអភិវឌ្ឍកុមារតូចថ្នាក់ជាតិ(NECCD)
- ក្រុមការងារអភិវឌ្ឍន៍យុវជន (YDWG)
- ក្រុមការងារកំណែទម្រង់សាលារៀន (SRWG)
- ក្រុមការងារអប់រំបឋមសិក្សា (PEWG)
- ការអប់រំក្នុងគ្រាអាសន្ន (EiE)
- កម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ - ការផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ (GPE KIX)
- ក្រុមការងារគ្រប់គ្រងសាលារៀនសុវត្ថិភាព របស់ក្រសួងអប់រំ។

Launching Ceremony
" FastTrack Road Map for Improving Nutrition 2025-2030"
Sokha Phnom Penh Hotel, 13th June 2025

៩. របាយការណ៍ហិរញ្ញវត្ថុ





១០. សេចក្តីថ្លែងអំណរគុណ

អង្គការ អេហ្វ អេក កម្ពុជា ...

អង្គការ អេហ្វ អេក កម្ពុជា សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយទាំងអស់ដែលបានបរិច្ចាគធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគមន៍ឱ្យមានភាពធន់ និងរីកចម្រើន។ យើងសង្ឃឹមថា នឹងមានការបន្តគាំទ្រពន្ធកិច្ចនេះ ដើម្បីនិរន្តរភាពយូរអង្វែងរបស់សហគមន៍គោលដៅ។

សូមទំនាក់ទំនងមកកាន់

fhcambodia.org

+855-23-215-046/047

cambodia@fh.org

ដើរជាមួយសហគមន៍

FH CAMBODIA